**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# សុន្ទរកថា

**របស់កិត្តិសេដ្ឋាបណ្ឌិត គាត ឈន់ ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ថ្លែងនៅក្នុងពិធីបិទ**

**«កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ»**

**រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៥**

-ឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

***-ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ភ្ញៀវជាតិ និងអន្តរជាតិ ជាទីមេត្រី!***

១- ខ្ញុំពិតជាមានសេចក្ដីសោមនស្សរីករាយក្រៃលែង ដោយបានចូលរួមជាមួយ **ឯកឧត្តម, លោកជំទាវ, អស់លោក, លោកស្រី, ភ្ញៀវជាតិ និងអន្តរជាតិ** ទាំងអស់ នៅក្នុង «**កិច្ចប្រជុំ ត្រួតពិនិត្យប្រចាំឆ្នាំនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**»។ ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះការរៀបចំ, ការដឹកនាំ និងការចូលរួមយ៉ាងសកម្ម, ប្រកបដោយស្មារតីសហការ និងការទទួលខុសត្រូវខ្ពស់ របស់ឯកឧត្តម, លោកជំទាវ, លោក, លោកស្រីទាំងអស់, ដែលបានធ្វើឱ្យកិច្ចប្រជុំរបស់យើងទទួលបានផ្លែផ្កា និងសម្រេច ជោគជ័យ តាមការគ្រោងទុក។ ខ្ញុំមានជំនឿថា ឯកឧត្តម, លោកជំទាវ, លោក, លោកស្រីទាំងអស់ ក៏មានការយល់ឃើញ និងវាយតម្លៃដូចខ្ញុំដែរ។

**២**- ឯកឧត្តមបណ្ឌិត **សុខ សារាវុឌ្ឍ** ក្នុងនាមជាប្រធានអគ្គលេខាធិការដ្ឋាន និងឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** ក្នុងនាមជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានធ្វើការបូកសរុបលទ្ធផល និងធ្វើសេចក្ដីសន្និដ្ឋាននៃកិច្ចប្រជុំយ៉ាង

ច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ ដែលរួមមាន លទ្ធផលសម្រេចបាន, បញ្ហាប្រឈម, អនុសាសន៍ និងសំណូមពរ ព្រមទាំងបានធ្វើការណែនាំសម្រាប់ការបន្តជំរុញអនុវត្តបញ្ចប់ដំណាក់កាលទី២ នៅចុងឆ្នាំ២០១៥ នេះ និងការបន្តរៀបចំឯកសារពាក់ព័ន្ធទាំងឡាយ, ជាពិសេស ការបន្តរៀបចំផែនការសកម្មភាពរួមនៃដំណាក់កាលទី ៣ (Consolidated Action Plan for Stage 3-CAP3) និងផែនការសកម្មភាពរបស់អគ្គនាយកដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (General Directorate Action Plan for Stage 3-GDAP3) ព្រមទាំងផែនការសកម្មភាពរបស់ក្រសួង- ស្ថាប័ន (Ministry Action Plan for Stage 3-MAP3) ឱ្យបានទាន់ពេលវេលា សម្រាប់ការឈានទៅចាប់ផ្តើមដំណាក់កាលទី៣ នៅដើមឆ្នាំ២០១៦ ខាងមុខ។

៣- ខ្ញុំពិតជាមានអារម្មណ៍រំភើប ដោយឃើញកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់យើងបានឈានមកដល់ចំណុចរបត់ដ៏សំខាន់ នោះគឺការចាប់ផ្តើមធ្វើការផ្លាស់ប្តូរប្រព័ន្ធតែម្តង, ពិសេសការផ្លាស់ប្តូរពីប្រព័ន្ធថវិកាផ្តោតលើមាតិកា ឬធាតុចូល និងមជ្ឈការ ទៅប្រព័ន្ធថវិកាផ្តោតលើលទ្ធផល ឬធាតុចេញ និងវិមជ្ឈការ ស្របតាម **«ទស្សនាទានស្តីពីការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា ២០១៣-២០២០»** របស់រាជរដ្ឋាភិបាល។ តាមរយៈនៃកិច្ចប្រជុំត្រួតពិនិត្យរយៈពេល ២ ថ្ងៃកន្លងទៅនេះ, ជាមួយនឹងការធ្វើបទបង្ហាញ, បទអន្តរាគមន៍ និងការពិភាក្សាយ៉ាងល្អិតល្អន់, ទាំងនៅក្នុងក្រុមតូច និងក្រុមធំ, ព្រមទាំងការបូកសរុប, ការសន្និដ្ឋាន នងការវាយតម្លៃប្រកបដោយវិជ្ជាជីវៈ និងភាពគ្រប់ជ្រុងជ្រោយ, ក៏ដូចជាការដាក់ចេញ, លើមូលដ្ឋាននៃការសំយោគប្រកបដោយគតិបណ្ឌិតនេះ, នូវវិធានការសម្រាប់កិច្ចដំណើរការបន្ត ប្រកបដោយភាពច្បាស់លាស់ថែមទៀតនោះ, ខ្ញុំពិតជាពុំមានអ្វី បន្ថែមទៅលើចំណាត់ការទាំងអស់នេះ ក្រៅអំពីការអបអរសាទរប្រកបដោយមោទនភាព និងប្រកបដោយជំនឿមុតមាំថា យើងពិតជានឹងអាចឈានទៅបញ្ចប់ដំណាក់កាលទី ២ ហើយចាប់ផ្តើមដំណាក់កាលទី ៣ បានប្រកបដោយជោគជ័យ តាមការគ្រោងទុក។

***ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!***

៤- ខ្ញុំពិតជាឯកភាពទាំងស្រុង ទៅនឹងប្រសាសន៍វាយតម្លៃដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ថា សមិទ្ធផលនៃកិច្ចការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងរយៈពេលដប់ឆ្នាំកន្លងទៅ គឺមិនត្រឹមតែគួជាទីលើកទឹកចិត្តប៉ុណ្ណោះទេ តែពិតជាគួជាទីមោទនៈប្រាកដមែន។ ខ្ញុំក៏យល់ស្របផងដែរ ជាមួយការលើកឡើង

របស់ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** នូវបណ្ដាចំណុចខ្លាំងទាំង ៦ ដែលនាំឱ្យយើងសម្រេចបានជោគជ័យកន្លងមក។ ទន្ទឹមនឹងនេះ ខ្ញុំសូមឱ្យកិច្ចប្រជុំទាំងមូលមេត្តាយកការណែនាំ និងអនុសាសន៍ទាំង ១២ ប្រការ របស់សម្ដេចតេជោនាយករដ្ឋមន្ត្រី ទៅអនុវត្តដោយម៉ឺងម៉ាត់ និងប្រកបដោយប្រសិទ្ធភាព ក្នុងការបន្តជំរុញការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យសម្រេចបានជោគជ័យ តាមការគ្រោងទុក។ លើសពីនេះទៅទៀត ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** ក្នុងនាមជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលបានដឹកនាំគណៈកម្មាធិការនេះប្រកបដោយជវភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ញាំងឱ្យការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រេចបានជោគជ័យយ៉ាងត្រចះត្រចង់នាពេលកន្លងមក ព្រមទាំងបានចង្អុលនូវទិសដៅយុទ្ធសាស្រ្តសម្រាប់រយៈពេល ១០ ឆ្នាំទៅមុខ យ៉ាងច្បាស់លាស់ និងប្រាកដនិយម ជាមួយនឹងការផ្ដល់នូវអនុសាសន៍ដ៏មានតម្លៃសម្រាប់ការបន្តជំរុញអនុវត្តបញ្ចប់ដំណាក់កាលទី ២ នងការត្រៀមរៀបចំលក្ខណៈសម្បត្ដើម្បីអាចចាប់ផ្ដើមដំណាក់កាលទី ៣ នៅដើមឆ្នាំ ២០១៦ ខាងមុខ នេះ បានប្រកបដោយជោគជយ។

**៥-** ពិតណាស់ថា ការអនុវត្តកិចការកែទម្រង តែងត្រូវជួបប្រទះនឹងឧបសគ្គ ព្រមទាំងបញ្ហាប្រឈមនានា ជាការណ៍ធម្មតាចៀសមិនផុត, ទាំងបញ្ហាបចេកទេស និងនយោបាយ។ យ៉ាងណាក៏ដោយ យើងក៏ធ្លាប់មានបទពិសោធន៍ឆ្លងកាត់ដោយជោគជ័យរួចហើយដែរ នូវដំណាក់កាលកែទម្រង់ដ៏សំខាន់ក្នុងរយៈពេលកន្លងមក។ ម្យ៉ាងវិញទៀត ភាពស្មុគស្មាញ និងការលំបាកជាសត្យានុម័តនានានៅលើវិថីនៃការកែទម្រង់ ក៏មិនមែនជាបញ្ហាសម្រាប់តែកម្ពុជាម្នាក់ឯងនោះដែរ, ដូចប្រសាសន៍របស់សម្ដេចតេជោនាយករដ្ឋមន្ត្រីថាៈ ***«គ្មានលទ្ធផលណាដែលបានមក ដោយមិនមានការបង់ថ្លៃនោះទេ, ហើយក៏គ្មាន ការកែទម្រង់ណាដែលសម្រេចបានដោយមិនមានការលះបង់នោះដែរ»***។ ក្នុងន័យនេះ, ខ្ញុំគិតថា យើងពិតជាមានសំណាង ដោយសារតែនៅក្នុងការអនុវត្តការងារដ៏លំបាកស្មុគស្មាញទាំងអស់នេះ, យើងមិន គ្រាន់តែទទួលបាននូវការគាំទ្រជានយោបាយយ៉ាងពេញទំហឹង ពីសម្ដេចតេជោនាយករដ្ឋមន្ត្រីប៉ុណ្ណោះទេ, ក៏ប៉ុន្តែ ថែមទាំងទទួលបាននូវការលើកទឹកចិត្ត, ការណែនាំចង្អុលបង្ហាញជាប្រចាំ, និងលើសពីនេះ, ទទួលបាននូវគំរូវរភាពក្នុងការគោរពវិន័យថវិកា ព្រមទាំងការប្ដេជ្ញាចិត្តមោះមុតឥតរាថយក្នុងការជំរុញ អនុវត្តការងារកែទម្រង់ឱ្យខាងតែសម្រេចបានជោគជ័យថែមទៀតផង។ យើងទាំងអស់គ្នាជាមន្ត្រីនៃរាជរដ្ឋាភិបាល ត្រូវតែចងចាំជាប់ជានិច្ចនូវជាសារនយោបាយគន្លឹះ និងជាយុទ្ធសាស្ត្រ របស់សម្ដេចតេជោនាយករដ្ឋមន្ត្រី គឺៈ ***«បើកែទម្រង់ គឺរស់,***

***តែបើមិនកែទម្រង់ គឺស្លាប់»***។ ដូច្នេះ, ក្នុងនាមគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ខ្ញុំចង់រំលឹកជាថ្មីម្តងទៀត អំពីភាពចាំបាច់នៃ **តួនាទីនាំមុខ** របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការដឹកនាំការងារកែទម្រង់របស់គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រង ហិរញ្ញវត្ថុ ក៏ដូចជា **តួនាទីជាតួអង្គគន្លឹះ** ដែលត្រូវតែបុរេសកម្ម, មានភាពជាម្ចាស់ និងមានការ ទទួលខុសត្រូវខ្ពស់របស់គ្រប់ក្រសួង-ស្ថាប័ន ដែលជាកត្តាគន្លឹះកំណត់ជោគជ័យនៃការកែទម្រង់ នេះ។ ទន្ទឹមនេះ ខ្ញុំក៏សូមអំពាវនាវឱ្យបណ្តាដៃគូអភិវឌ្ឍន៍របស់យើង បន្តផ្តល់ការគាំទ្រចាំបាច់នានា, ទាំងជាហិរញ្ញប្បទាន ទាំងជាជំនួយបច្ចេកទេស, ប្រកបដោយសុឆន្ទៈ និងប្រកបដោយចរភាព ចំពោះការកែទម្រង់នេះ ឱ្យសម្រេចបានជោគជ័យតាមការគ្រោងទុក ក្នុងស្មារតីនៃការគោរព និង លើកតម្កើងភាពជាម្ចាស់របស់កម្ពុជា។

**៦**-ជាទីបពាប់, ខ្ញុំសូមគោរពថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះឯកឧត្តម, លោកជំទាវ, លោក, លោកស្រី ដែលបានចូលរួមយ៉ាងសកម្ម ព្រមទាំងបានផ្តល់នូវវិភាគទានជាបញ្ញាញាណ, ជាមតិយោបល់ និង អនុសាសន៍ដ៏មានតម្លៃនានា ដល់កិច្ចប្រជុំត្រួតពនិត្យប្រចាំឆ្នាំក្នុងរយៈពេល ២ ថ្ងៃកន្លងទៅនេះ ដែលធ្វើឱ្យកិច្ចប្រជុំដំណើរការប្រកបដោយជោគជ័យ និងសម្រេចបានលទ្ធផល តាមការរំពឹងទុក។ លទ្ធផលដែលកើតចេញពីកចប្រជុំនេះ គឺពិតជាធាតុចូលដ៏មានតម្លៃសម្រាប់រួម ចំណែកដល់ការកែលម្អឱ្យកាន់តែប្រសើរឡើងនូវឯកសារពាក់ព័ន្ធទាំងឡាយ និងជាពិសេស រួមចំណែក កែលម្អ និងបង្កើនស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព នៅក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈរបស់រាជរដ្ឋាភិបាល។ ខ្ញុំ សូមគោរពជូនពរដល់ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី ទាំងអស់ សូមប្រកបដោយសុខភាពល្អបរិបូណ៌ សិរីមង្គល វិបុលភាព ជាភិយ្យោភាព និងសម្រេចបាន ជោគជយគ្រប់ភារកិច្ច តាមមុខសញ្ញារៀងៗខ្លួន ដែល**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ប្រគល់ជូន។ ខ្ញុំរួមជាមួយគណៈអធិបតី និងអង្គពិធី ទាំងមូល សូមប្រកាសបិទ **«កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈ»** នាពេលនេះ!

***សូមអរគុណ!***